អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ ថៃមានបំណងបំបាត់អក្សរខ្មែរដោយបង្ខំ
## លោកជ័យ-មង្គលបង្រៀនភាសាខ្មែរជាអក្សរថៃ ។

**Website: www.hoksavann.org**

ថ្ងៃទី២២ មីនា ២០១០



យើងបានទទួលដំណឹងជាបន្តបន្ទាប់ថា លោកជ័យ-មង្គលជាជនជាតិខ្មែរនៅខេត្តសុរិន្ទប្រទេសថៃ បានបើកបង្រៀនអក្សរខ្មែរនៅទីនោះជាច្រើនថ្នាក់ អស់ពេលជាយូរឆ្នាំមកហើយ រហូតខ្មែរដែលបានរៀនពីលោកចេះអានចេះសរសេរជាមធ្យមទៀតផង ។ ផែនការបង្រៀននេះ កើតចេញពីគំនិតរបស់លោក ដោយលោកចង់ឲ្យជនជាតិខ្មែរនៅប្រទេសថៃចេះអក្សរខ្មែរកុំឲ្យបាត់បង់ ។ ការបង្រៀនរបស់លោកមានលក្ខណៈជាឯកជន ពុំមែនបង្រៀនក្នុងសាលារដ្ឋរបស់ប្រទេសថៃឡើយ ។ ការបង្រៀននេះអាចប្រព្រឹត្តទៅបាន ដោយវិភាគទានរបស់សិស្ស និងមានការឧបត្ថម្ភខ្លះពីខ្មែរនៅក្រៅប្រទេស ។ យើងសូមកោតសរសើរ អំពីឧត្តមគតិដ៏ជ្រាលជ្រៅរបស់លោកជ័យ-មង្គល ហើយយើងសូមជូនពរ សូមឲ្យបំណងរបស់លោកបានសំរេចជោគជ័យ ។ ឥឡូវនេះ ការបង្រៀនមានបញ្ហាខ្លះ ដោយអាជ្ញាធរថៃនៅខេត្តសុរិន្ទបានតម្រូវឲ្យលោកបង្រៀនអក្សរខ្មែរដោយយកអក្សរថៃជាយាន គឺសរសេរជាអក្សរថៃ ។ លោកជ័យ-មង្គលពុំព្រម បានសរសេរសំបុត្រតវ៉ាទៅរដ្ឋមន្ត្រីក្រសួងអប់រំថៃ ។

តាមច្បាប់អង្គការសហប្រជាជាតិ បានតម្រូវឲ្យគ្រប់ប្រទេសទាំងអស់ក្នុងសកលលោក បើកសិទ្ធិឲ្យជនជាតិភាគតិចនៅក្នុងប្រទេសរបស់ខ្លួន រក្សាប្រពៃណីទំនៀមទំលាប់ សាសនា អក្សរសាស្ត្រ ដោយគ្មានការរារាំង ថែមទាំងត្រូវជួយឧបត្ថម្ភទៀតផង ។ ចំពោះប្រទេសថៃ យើងបានដឹងគ្រប់គ្នាហើយ គឺប្រទេសនេះបានប្លន់យកទឹកដីខ្មែរអស់ជាច្រើនខេត្ត ថែមទាំងមានផែនការបំបាត់វប្បធម៌ខ្មែរទៀតផង ។ កាលជំនាន់ដើម នៅបាងកក បើឮខ្មែរណានិយាយភាសាខ្មែរ អាជ្ញាធរថៃនឹងចាប់លក់ជាច្រើនរយបាត្រ ។ តាមសាវតា ខ្មែរជាគ្រូរបស់ថៃ ដោយថៃបានចម្លងយកនូវវប្បធម៌ខ្មែរជាច្រើន ដូចជាយកអក្សរខ្មែរមកច្នៃជាអក្សរថៃសព្វថ្ងៃនេះ ដោយលុបសក់ចោល ហើយពាក្យជាច្រើនជាពាក្យរបស់ខ្មែរ គ្រាន់តែអានតាមសំនៀងរបស់ភាសាថៃប៉ុណ្ណោះ ។ ឥឡូវនេះ កូនសិស្សមើលងាយលោកគ្រូ ដោយសារតែរាជាណាចក្រខ្មែរបានត្រូវចុះទន់ខ្សោយ ។ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយ គេសង្កេតឃើញពលរដ្ឋថៃហាក់ដូចជានៅគោរពឥទ្ធិពលរបស់ខ្មែរ ដូចជាគោរពអក្សរមូលខ្មែរ (អក្សរក្បាច់ខ្មែរ) ថាជាអក្សរស័ក្តិសិទ្ធិក្នុងមន្តអាគមគាថា សរសេរជាអក្សរមូលខ្មែរទើបពូកែស័ក្តិសិទ្ធិ ។

បើថៃបង្ខំឲ្យលោកជ័យ-មង្គលបង្រៀនភាសាខ្មែរសរសេរជាអក្សរថៃ ជាការបំបាត់អក្សរខ្មែរ រំលោភលើច្បាប់អង្គការសហប្រជាជាតិ ។ ផ្ទុយទៅវិញ ភាសានិងអក្សរថៃមានបើកបង្រៀនជាច្រើនថ្នាក់នៅប្រទេសកម្ពុជា បើថៃនៅតែបង្ខំឲ្យលោកជ័យ-មង្គលបង្រៀនភាសាខ្មែរជាអក្សរថៃ ត្រូវតែរាជរដ្ឋាភិបាលខ្មែរបិទសាលាថៃដែលបង្រៀននៅប្រទេសកម្ពុជា ឬតម្រូវឲ្យរៀនភាសាថៃជាអក្សរខ្មែរដូចគ្នាដែរ ។

យើងសង្កេតឃើញថា វប្បធម៌ខ្មែរនិងវប្បធម៌ថៃមានលក្ខណៈស្រដៀងគ្នា ដូចជាព្រះពុទ្ធសាសនាជាដើម បានជាធ្វើឲ្យជនជាតិខ្មែររាប់លាននាក់ដែលរស់នៅប្រទេសថៃ ហាក់ដូចជារស់នៅដោយស្ងប់ស្ងៀមជាមួយវប្បធម៌ថៃ ដោយគ្មានការរើបំរះរក្សាវប្បធម៌របស់ជាតិខ្លួនឡើយ គឺហាក់ដូចជាដេកលក់ ដូចពាក្យខ្មែរថា ក្តៅស៊ីរាក់ត្រជាក់ស៊ីជ្រៅ ឬដូចពាក្យមួយទៀតថា ស្រមោចពុំស្លាប់ក្នុងពាងអំបិលទេ តែវាស្លាប់ក្នុងពាងស្ករ ។ នេះជាលើកទី១ដែលលោកជ័យ-មង្គលបានក្រោកឡើងចាប់បង្រៀនភាសានិងអក្សរខ្មែរនៅទីនោះ ទាន់ពេលដែលអង្គការសហប្រជាជាតិបានថ្កោលទោសចំពោះប្រទេសណាដែលរំលោភសិទ្ធិនៃជនជាតិភាគតិច ទោះទង្វើនេះថៃមិនពេញចិត្តនិងមិនគាំទ្រក៏ដោយ ។ ផ្ទុយទៅវិញជនជាតិខ្មែរកម្ពុជាក្រោមបានក្រោកឡើងបង្រៀនអក្សរខ្មែរនៅតាមវត្ត ទោះបីវៀតណាមគំរាមកំហែងក៏ដោយ ព្រោះវប្បធម៌ខ្មែរនិងវប្បធម៌វៀតណាមមានលក្ខណៈផ្សេងគ្នា ហើយប្រទេសវៀតណាមជាប្រទេសកុម្មុយនិស្ត ពុំគោរពច្បាប់អង្គការសហប្រជាជាតិ អំពីសិទ្ធិនៃជនជាតិភាគតិចឡើយ ។

ចំពោះរាជរដ្ឋាភិបាលខ្មែរស្ទើរគ្រប់សម័យ ពុំសូវយកចិត្តទុកដាក់ដល់ជនជាតិខ្មែរដែលរស់នៅប្រទេសថៃនិងប្រទេសវៀតណាម ដោយចាត់វិធានការយ៉ាងណាឲ្យជនជាតិរបស់ខ្លួនរក្សានូវវប្បធម៌ មានភាសានិងអក្សរសាស្ត្រខ្មែរជាដើមឲ្យបានគង់វង់ឡើយ ។ នៅកម្ពុជាក្រោម ទោះបីវៀតណាមគាបសង្កត់មិនចង់ឲ្យខ្មែររៀនអក្សរខ្មែរនិងក៏រិតការប្រតិបត្តិព្រះពុទ្ធសាសនា ដូចជាបុណ្យកឋិនឲ្យធ្វើតែមួយថ្ងៃជាដើម ក៏រាជរដ្ឋាភិបាលខ្មែរធ្វើមិនដឹងមិនឮ គ្មានជួយធ្វើអន្តរាគមន៍អ្វីសោះដល់វៀតណាមកុំឲ្យរំលោភសិទ្ធិមនុស្សបែបនេះ ។ ជនជាតិខ្មែរនៅប្រទេសថៃ មិនត្រឹមតែមិនចេះអក្សរខ្មែរជាអក្សរជាតិរបស់ខ្លួនប៉ុណ្ណោះទេ ភាសាខ្មែរជាភាសានិយាយចំពោះជនជាតិខ្មែរដែលមានអាយុពី៤០ឆ្នាំចុះមក ស្ទើរតែលែងចេះភាសាខ្មែរទៅហើយ ផ្នែកសិល្បៈគេឃើញលេចមុខជាងគេគឺភ្លេងកន្ទ្រឹមប៉ុណ្ណោះ ។ ដូច្នេះជនជាតិខ្មែរនៅប្រទេសថៃគប្បីក្រោកឡើងរកមធ្យោបាយសិក្សារៀនសូត្រប្រពៃណីទំនៀមទំលាប់អក្សរសាស្ត្រភាសាជាតិឲ្យបានចេះដឹងឡើង ដើម្បីរក្សាអត្តសញ្ញាណជាតិឲ្យបានគង់វង់ ។ រាជរដ្ឋាភិបាលខ្មែរមិនគួរព្រងើយកន្តើយតទៅទៀតទេ គួរលើកកម្លាំងទឹកចិត្តនិងជួយឧបត្ថម្ភខ្មែរទាំងពីរប្រទេសនេះ ឲ្យរក្សាវប្បធម៌របស់ខ្លួនបាន ។៚